ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខៈ ៧៨៤ អក

ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧

សាលក្រមព្រហ្មទណ្ឌលេខ:១១២ (ជជ)

ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០១៨

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង ០៩ ព្រឹក ដោយមានសមាសភាពចូលរួមដូចខាងក្រោម ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹង**

លោក [redacted] សមាជិកគណៈមេធាវី

លោក [redacted] និង [redacted] សមាជិកគណៈមេធាវី

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ**

លោក [redacted] សមាជិកគណៈមេធាវី (អវត្តមាន)

-ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខៈ ៧៨៤ អក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៧ ដែលមានជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា ភេទស្រី អាយុ ៥០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ គ្រូបង្រៀន មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សុទ្ធ (ស) ម្ដាយឈ្មោះ [redacted] លី (ស) ប្ដីឈ្មោះ [redacted] សារឿន មានកូន ០៣នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ត្រូវចោទពីបទៈ ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅភូមិពពែរ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្ដាល កាលពីខែធ្នូ ឆ្នាំ ២០១៦ តាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងបទ ប្រឆាំងអ្នករាជការសាធារណៈ ប្រព្រឹត្តនៅភូមិពពែរ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្ដាល កាលពីអំឡុងខែមករា ឆ្នាំ ២០១៧ តាមបញ្ញត្តិមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធរណី ភេទប្រុស អាយុ ៦២ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ២២ហ្ប៊ី ផ្លូវលេខ ៥៨៩ ភូមិទួលគោក សង្កាត់ទួលសង្កែ រាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៖ ៩៤៣ ដកសស ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៖ ៥២៦ ដកសព ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ ដីកាដំណោះស្រាយលេខ៖ ៥២២ ដកដស ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៨ របស់ចៅក្រមស៊ើបសួរ ។

## អំពើប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០០៨ ឈ្មោះ[redacted] ធរណី បានទិញដីមួយកន្លែង ស្ថិតនៅភូមិពពែរ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល ពីឈ្មោះ [redacted] សុទ្ធ និងកូនស្រីឈ្មោះ [redacted] ច័ន្ទបូផា ដោយធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ហើយបានប្រគល់ប្រាក់នៃការទិញលក់ដីនោះគ្រប់ចំនួនរួចរាល់ និងមានការទទួលស្គាល់ពីអាជ្ញាធរឃុំ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០០៨ ព្រមទាំងអភិបាលស្រុកពញាឮ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០០៨ ថែមទៀតផង ។ ហើយកាលពីអំឡុងខែធ្នូ ឆ្នាំ ២០១៦ ឈ្មោះ[redacted] ធរណី បានចុះទៅធ្វើការវាស់វែងដីនោះ ដែលមានការចូលរួមពីអាជ្ញាធរថ្នាក់មូលដ្ឋានមន្ត្រីជំនាញនៃការិយាល័យភូមិបាលស្រុក និងអ្នកតំណាងឈ្មោះ [redacted] មួន ប៉ុន្តែនៅពេលកំពុងវាស់វែង ឈ្មោះ [redacted] ច័ន្ទបូផា និងបក្សពួកប្រហែលជា ៤ទៅ៥នាក់ បានមកធ្វើការរារាំង និងហាមឃាត់មិនឲ្យធ្វើការវាស់វែងដីនោះឡើយ ហើយឈ្មោះ [redacted] ច័ន្ទបូផា បានលើកឡើងថាដីនោះមិនទាន់ឲ្យប្រាក់គ្រប់ចំនួន ដូច្នេះខ្លួនមិនឲ្យធ្វើការវាស់វែងជាដាច់ខាត និងព្រមទាំងស្រែកគំរាមកំហែងថា ប្រសិនបើនៅតែបន្ត ពួកគេទាំងអស់គ្នានិងប្រើហិង្សា ។ ក្រោយមកនៅថ្ងៃទី ០២ ខែមករា ឆ្នាំ ២០១៧ ឈ្មោះ[redacted] ធរណី បានដាក់លិខិតស្នើសុំអង្កេត និងវាស់វែងដីនោះសារជាថ្មី ហើយក៏មានការឯកភាព ។ បន្ទាប់ពីទទួលបានការយល់ព្រមហើយ នៅក្នុងខែមករា ឆ្នាំ ២០១៧ ឈ្មោះ [redacted] មួន (ជាអ្នកតំណាង) និងអាជ្ញាធរ បានទៅធ្វើការវាស់វែងម្តងទៀត និងយកអាត្រាក់ទ័រទៅឈូសឆាយលើដីនោះ ។ ភ្លាមនោះស្រាប់តែឈ្មោះ[redacted] ច័ន្ទបូផា និងបក្សពួក បានមកធ្វើការអុកឡុកនិងគំរាមកំហែងប្រើហិង្សាលើក្រុមការងារម្តងជាពីរដង ហើយបានឃាត់ទុកអាត្រាក់ទ័រ ទុកនៅទីនោះទៀតផង ដោយឃើញសកម្មភាពបែបនោះ អាជ្ញាធរក៏ផ្អាកសកម្មភាពវាស់វែងរហូតមកដល់បច្ចុប្បន្ន ។

## នាពេលសវនាការ

១-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបូផា បានឆ្លើយថា: នៅថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០០៨ ខ្លួនមិនបានលក់ដីឲ្យឈ្មោះ [redacted] ធរណី ទេ ប៉ុន្តែឪពុកខ្លួនបានលក់ទៅឲ្យឈ្មោះ[redacted] សារ៉ុម ជាអ្នកគួកជេដី ប៉ុន្តែមិនស្គាល់ទីលំនៅទេ ។ នៅពេលធ្វើកិច្ចសន្យានោះ ឪពុករបស់ខ្លួនឈ្មោះ[redacted] សុទ្ធ ក៏បានផ្តិតមេដៃដែរ រីឯប្តីខ្លួនឈ្មោះ [redacted] សារឿន មិនចាំថាបានផ្តិតមេដៃឬទេ កិច្ចសន្យាដែលធ្វើនោះគឺនៅឆ្នាំ ២០០៨ ។ ចំពោះកិច្ចសន្យាលក់ផ្តាច់អចលនវត្ថុ និងផ្ទេរសិទ្ធិកាន់កាប់បន្ត ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០០៨ ដែលមានស្នាមមេដៃឈ្មោះ [redacted] សុទ្ធ ស្នាមមេដៃក្រុមគ្រួសារខ្លួន និងភាគីអ្នកទិញឈ្មោះ ច័ន្ទ ធរណី មានសាក្សីឈ្មោះ គៀល សុខ និងឈ្មោះ [redacted] មួន នោះគឺខ្លួនមិនទទួលស្គាល់ទេ ។ រីឯឪពុកខ្លួន ក៏ពុំបានធ្លាប់លក់ដីឲ្យទៅឈ្មោះ[redacted] ធរណី ដែរ គឺគាត់លក់ឲ្យឈ្មោះ[redacted] ក សារ៉ុម ។ ខ្លួននិងឪពុក ធ្លាប់ទទួលប្រាក់កក់ពីឈ្មោះ[redacted] សារ៉ុម ចំនួន ៥៥០០ ដុល្លារអាមេរិក ជាថ្លៃដី ។នៅថ្ងៃកើតហេតុ ខ្លួនពិតជាបានទៅឃាត់ឈ្មោះ [redacted] ធរណី មិនឲ្យឈូសឆាយ ឬវាស់វែងបោះបង្គោលព្រំនៅលើដីនោះមែន ។



Scanned with CamScanner

២-តាមពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធរណី បានថ្លែងថា: កាលពីថ្ងៃទី ១១ ខែមីនា ឆ្នាំ ២០០៨ ខ្លួនបានទិញដីមួយកន្លែង ស្ថិតនៅភូមិពពែរ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល ពីឈ្មោះ [redacted] សុខុ និងកូនស្រីឈ្មោះ [redacted] ច័ន្ទបុផា ដោយបានធ្វើលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ហើយបានប្រគល់ប្រាក់នៃការទិញលក់ដីនោះគ្រប់ចំនួនរួចរាល់ និងមានការទទួលស្គាល់ពីអាជ្ញាធរឃុំ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០០៨ ព្រមទាំងអភិបាលស្រុកពញាឮ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ ២០០៨ ថែមទៀតផង ។ ហើយកាលពីអំឡុងខែធ្នូ ឆ្នាំ ២០១៦ ខ្លួនបានចុះទៅធ្វើការវាស់វែងដីនោះ ដែលមានការចូលរួមពីអាជ្ញាធរថ្នាក់មូលដ្ឋានមន្ត្រីជំនាញនៃការិយាល័យភូមិបាលស្រុក និងអ្នកតំណាងឈ្មោះ [redacted] មួន ប៉ុន្តែនៅពេលកំពុងវាស់វែង ឈ្មោះ [redacted] ច័ន្ទបុផា និងបក្សពួកប្រហែលជា ៤ទៅ៥នាក់ បានមកធ្វើការរារាំង និងហាមឃាត់មិនឲ្យធ្វើការវាស់វែងដីនោះឡើយ ហើយឈ្មោះ [redacted] ច័ន្ទបុផា បានលើកឡើងថាដីនោះមិនទាន់ឲ្យប្រាក់គ្រប់ចំនួន ដូច្នេះខ្លួនមិនឲ្យធ្វើការវាស់វែងជាដាច់ខាត និងព្រមទាំងស្រែកគំរាមកំហែងថា ប្រសិនបើនៅតែបន្ត ពួកគេទាំងអស់គ្នានិងប្រើអំពើហិង្សា ។ មិនត្រឹមតែប៉ុណ្ណោះ ពួកគេបានជេរប្រមាថមកលើក្រុមការងាររបស់ខ្លួនក៏ដូចជាអាជ្ញាធរដែលកំពុងតែអនុវត្តការងារផងដែរ ។ចាប់ពីពេលនោះមក ដីនោះគឺបានទុកចោលមួយរយៈ ប៉ុន្តែក្រោយមកនៅថ្ងៃទី ០២ ខែមករា ឆ្នាំ ២០១៧ ខ្លួន បានដាក់លិខិតស្នើសុំអង្កេត និងវាស់វែងដីនោះសារជាថ្មី ហើយក៏មានការឯកភាព និងទទួលស្គាល់ពីមេភូមិជ្រៃលាស់រួមទាំងចំណារពីអភិបាលស្រុកពញាឮផងដែរ ។ ក្រោយពីទទួលបានការយល់ព្រមហើយ នៅក្នុងខែមករា ឆ្នាំ ២០១៧ ឈ្មោះ [redacted] មួន (ជាអ្នកតំណាង) និងលោកមេភូមិពពែរ លោកមេឃុំជ្រៃលាស់ និងមន្ត្រីភូមិបាល បានទៅធ្វើការវាស់វែងម្តងទៀត និងយកគ្រាក់ទ័រទៅឈូសឆាយលើដីនោះ ដើម្បីធ្វើការកំណត់ព្រំឲ្យបានច្បាស់លាស់ជៀសវាងក្នុងការកើតជម្លោះ ពីព្រោះដីនោះបានទិញចំនួនពីរម្ចាស់ជាប់គ្នា ពីឈ្មោះ [redacted] ហួរ ,ឈ្មោះ [redacted] សុខុ និងកូនស្រីឈ្មោះ [redacted] ច័ន្ទបុផា ។ នៅពេលកំពុងធ្វើការឈូសឆាយ ភ្លាមៗនោះស្រាប់តែឈ្មោះ [redacted] ច័ន្ទបុផា និងបក្សពួក ប្រហែល ០៤ ទៅ ០៥នាក់ដដែល បានមកធ្វើការអុកឡុក និងគំរាមកំហែងប្រើប្រាស់អំពើហិង្សាមកលើក្រុមការងាររបស់ខ្លួន ម្តងជាពីរដង ហើយបានឃាត់ទុកអាគ្រាក់ទ័រ នៅទីនោះទៀតផង ដោយឃើញសកម្មភាពបែបនោះ អាជ្ញាធរ និងមន្ត្រីភូមិបាល ក៏បានផ្អាកការវាស់វែង រហូតមកដល់បច្ចុប្បន្ន ។ ទង្វើរបស់ឈ្មោះ [redacted] ច័ន្ទបុផា ជាអំពើរំលោភមកលើសិទ្ធិស្របច្បាប់របស់ខ្លួនធ្ងន់ធ្ងរ ដែលខ្លួនជាម្ចាស់ដីស្របច្បាប់ និងទទួលបានការផ្ទេរសិទ្ធិកាន់កាប់ដីត្រឹមត្រូវពីអាជ្ញាធរមូលដ្ឋានរួចរាល់ហើយនោះ ។ ខ្លួនទាមទារជម្ងឺចិត្ត និងសំណងការខូចខាតចំនួន ៣០,០០០ដុល្លារ(បីម៉ឺនដុល្លារអាមេរិក) ។

៣-មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានថា៖ នាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា បានអវត្តមាន ហើយបានឆ្លើយនៅដំណាក់កាលអយ្យការ ក៏ដូចជាដំណាក់កាលចៅក្រមស៊ើបសួរថា ខ្លួនអត់បានលក់ដីទេ តែតាមលិខិតលក់ទិញមានស្នាមមេដៃឈ្មោះ [redacted] សុខុ ដែលជាឪពុក និងឈ្មោះ [redacted] ច័ន្ទបុផា ហើយនៅពេលកូនក្តីខ្លួនទៅឈូសឆាយដី ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា បានទៅរារាំង ។ ដូច្នេះឃើញថាជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ដោយសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់ និងសុំទាមទារសំណងទៅតាមការទាមទាររបស់កូនក្តីខ្លួន ។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ និងអំណានចម្លើយក្នុងពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឃើញថាជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា ពិតជាបាន ប្រើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត តាមមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងបទ ប្រឆាំងនឹងអ្នករាជការសាធារណៈ តាមមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ ពិតប្រាកដមែន ដូច្នេះតំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល ។

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានថ្លឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានពិនិត្យភស្តុតាងនានា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តកណ្តាល

## យល់ឃើញថា

១-អំពើប្រើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងអំពើប្រឆាំងអ្នករាជការសាធារណៈ គឺជាការប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងប្រឆាំងអ្នករាជការដែលកំពុងបំពេញការងារ ហើយអំពើនេះធ្វើឲ្យប៉ះពាល់ ដល់របៀបរៀបរយសាធារណៈ និងសន្តិសុខសណ្តាប់ធ្នាប់សង្គម ដែលច្បាប់បានហាមឃាត់ និងបញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា ជានីតិជនមានស្មារតីល្អគ្រប់គ្រាន់ដែលអាចដឹង និងទទួលខុសត្រូវនូវអំពើប្រព្រឹត្តរបស់ខ្លួនបាន ។

៣- ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា ដែលបានឆ្លើយថា នៅថ្ងៃកើតហេតុ ខ្លួនពិតជាបានទៅឃាត់ឈ្មោះ [redacted] ធរណី មិនឲ្យឈូសឆាយ ឬវាស់វែង បោះបង្គោលព្រំ នៅលើដីនោះប្រាកដមែន ចម្លើយនេះអាចឲ្យតុលាការជឿបាន ព្រោះស្របនិងចម្លើយរបស់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី ហើយក៏ស៊ីសង្វាក់ទៅនិងឯកសារគតិយុត្តិផ្សេងៗនៅក្នុងសំណុំរឿងផងដែរ តែត្រង់ថា ខ្លួនមិនបានលក់ដីទំនាស់នេះឲ្យឈ្មោះ [redacted] ធរណីនោះ ចម្លើយនេះពុំអាចឲ្យតុលាការជឿបានឡើយ ព្រោះផ្ទុយនិងកិច្ចសន្យាលក់ផ្តាច់អចលនវត្ថុ និងផ្ទេរសិទ្ធិកាន់កាប់បន្ត ដែលមានស្នាមមេដៃរបស់ជនជាប់ចោទផ្ទាល់ និងមេដៃរបស់ឪពុកជនជាប់ចោទឈ្មោះ [redacted] សុទ្ធ និងប្តីរបស់ជនជាប់ចោទឈ្មោះ ចិន សារឿន និងសាក្សី ព្រមទាំងមានប្រថាប់ត្រាដឹងឮពីលោកមេភូមិ មេឃុំ និងអភិបាលស្រុកផងដែរ ។

៤-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធរណី ថា នៅថ្ងៃកើតហេតុជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា និងបក្សពួកប្រហែល ៤ទៅ៥ នាក់ បានមកធ្វើការរារាំង និងហាមឃាត់មិនឲ្យធ្វើការវាស់វែងដីនោះឡើយ ចម្លើយនេះមានភាពស៊ីចង្វាក់គ្នាជាមួយនិងចម្លើយរបស់ជនជាប់ចោទ ក៏ដូចជាឯកសារភស្តុតាងនានាដែលមានក្នុងសំណុំរឿងឃើញថា នៅថ្ងៃកើតហេតុជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា ពិតជាបានប្រើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងប្រឆាំងអ្នករាជការសាធារណៈ ពិតប្រាកដមែន ។

៥-តាមចម្លើយរបស់ជនជាប់ចោទ និងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ធៀបនិងឯកសារគតិយុត្តិផ្សេងៗនៅក្នុងសំណុំរឿងឃើញថា នៅពេលកើតហេតុជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ។

៦- មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋាន មានលក្ខណៈសមហេតុផលខ្លះ អាចឲ្យតុលាការទទួលយកមកពិនិត្យ និងពិចារណាបាន ។

៧-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន មានលក្ខណៈសមហេតុផល អាចឲ្យតុលាការទទួលយកមកពិនិត្យ និងពិចារណាបាន ។

៨-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា ភេទស្រី អាយុ ៥០ ឆ្នាំ ពីបទ៖ ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅភូមិពពៃរ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល កាលពីខែធ្នូ ឆ្នាំ ២០១៦ តាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងបទ ប្រឆាំងអ្នករាជការសាធារណៈ ប្រព្រឹត្តនៅភូមិពពៃរ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល កាលពីអំឡុងខែមករា ឆ្នាំ ២០១៧ តាមបញ្ញត្តិមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ ។

៩-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធរណី បានប្តឹងទាមទារសំណងជម្ងឺចិត្ត និងសំណងការខូចខាតចំនួន ៣០,០០០ ដុល្លារ(បីម៉ឺនដុល្លារអាមេរិក) ពីជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា ឃើញថាមានលកលក្ខណៈសមហេតុផលខ្លះ អាចឲ្យតុលាការទទួលយកមកពិនិត្យ និងសម្រេចតាមសភាពជាក់ស្តែង ។

## ***ហេតុដូច្នេះសម្រេច***

**១**-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា ភេទប្រុស អាយុ ៥០ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ១៨ខែ (ដប់ប្រាំបីខែ) ។

ពីបទ៖ ប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ប្រព្រឹត្តនៅភូមិពពៃរ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល កាលពីខែធ្នូ ឆ្នាំ ២០១៦ តាមបញ្ញត្តិមាត្រា ២៥៣ នៃច្បាប់ភូមិបាល និងបទ ប្រឆាំងអ្នករាជការសាធារណៈ ប្រព្រឹត្តនៅភូមិពពៃរ ឃុំជ្រៃលាស់ ស្រុកពញាឮ ខេត្តកណ្តាល កាលពីអំឡុងខែមករា ឆ្នាំ ២០១៧ តាមបញ្ញត្តិមាត្រា ៥០៣ នៃក្រមព្រហ្មទណ្ឌ ។

**២**-បង្គាប់មកជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា សងសំណងការខូចខាត និងសំណងជម្ងឺចិត្តចំនួន ៣០០០ដុល្លារ (បីពាន់ដុល្លារអាមេរិក) ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធរណី ។ ការប្តឹងទាមទារលើសពីនេះលកើចោល ។

**៣**- សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០១៨ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ច័ន្ទបុផា និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធរណី ។

ទុកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ច្បាប់ចម្លង
ថ្ងៃ 19.10.2018
លេខាធិការ
[redacted]

**ក្រឡាបញ្ជីសវនាការ** [redacted]

**ចៅក្រមជំនុំជម្រះ** [redacted]



Scanned with CamScanner